## *ក-សំភារៈប្រើប្រាស់*

១-ME ដបចំណុះ 10ml និង ថ្នាំពុលសំរាប់លាយដបតូចចំណុះ 01ml

២-ស៊ីរ៉ាំងចាក់ថ្នាំចំណុះ 05 ឬ 10ml

៣-ម្ជុលសំរាប់ បូមថ្នាំលេខ 18 ឬ 21 (ម្ជុលចាក់ថ្នាំធម្មតា មិនអាចបូមថ្នាំបានទេ) ។

៤-ស្រោមដៃ

៥-អន្ទាក់ធ្វើពីកំប៉ុងជ័រ ពណ៌សស្រអាប់ ។



## *ខ-របៀបប្រើប្រាស់*

១-យកថ្នាំពុលដបតូច(ចំណុះ01ml)ចាក់ចូលដប ME ចំណុះ 10ml គ្របឱ្យជិតក្រឡុកឱ្យសព្វ ។ អាចប្រើ ME ដោយមិនលាយថ្នាំពុលក៏បាន រុយចូលអន្ទាក់នោះ នឹងងាប់ដោយខ្លួនវា ២-៣ ថ្ងៃ បន្ទាប់

២-ប្រើស៊ីរ៉ាំង 05ml បំពាក់ម្ជុលបូមលេខ ១៨ បូមថ្នាំពីក្នុងដបចំនួន 01ml (បញ្ជាក់ដើម្បីបូមថ្នាំពីដបបានត្រូវយកស៊ីរ៉ាំងបំពាក់ម្ជុលរួច បូមខ្យល់ទទេចំនួន 01ml សិនរួចចាក់ម្ជុលទំលុះឆ្នុកដបជ័របាញ់ខ្យល់ 01ml ចូលក្នុងដប រួចបូមយកថ្នាំ 01ml មកវិញ) ។

៣-បើកគំរបអន្ទាក់យកថ្នាំដែលលាយហើយ 01ml ឬ ME ដោយមិនលាយថ្នាំពុលចំនួន 01ml នោះបាញ់ដាក់ទៅលើអេប៉ុង ឬ សំឡីក្នុងអន្ទាក់ជ័រនោះ រួចបិទគំរបអន្ទាក់វិញ ។



៤-យកអន្ទាក់នេះទៅព្យួរ នៅលើដើមឈើស៊ុបទ្រុបចៀសវាង ត្រូវកំដៅថ្ងៃ ដែលធ្វើឱ្យឆាប់បាត់បង់សារជាតិ ME និង ជាតិពុល

៥-លើផ្ទៃចំការ ១000មែត្រការ៉េ អាចប្រើអន្ទាក់ពី ២ ទៅ ៣ ក្រោយពីព្យួរ ៧ ថ្ងៃ ទៅ ២0ថ្ងៃ ត្រូវចាក់រុយចេញពីអន្ទាក់ហើយបន្ថែម ME ដែលលាយជាមួយថ្នាំពុល ឬ មិនលាយ 01ml ទៀត ។ ករណីក្នុងចំការ មានរុយចូលច្រើនត្រូវយកចាក់ចោល ៥-៧ ថ្ងៃម្តង

៦-ដប ME ដែលលាយថ្នាំពុលហើយ អាចទុកបានមិនលើសពី ៦ ខែឡើយ ។

មន្ទីរកសិកម្ម ខេត្តកណ្តាល

# រុយលើផ្លែឈើ និងបន្លែហូបផ្លែ

# (Fruit Fly)



រៀបចំដោយ : ការិយាល័យក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម

លេខ : ៤ ឆ្នាំ២00៨

## ១-ភាពចង្រៃ

បច្ចុប្បន្នពពួករុយលើផ្លែឈើ និង បន្លែហូបផ្លែត្រូវបាន ចាត់ទុកជា សត្វល្អិតចង្រៃចំបងក្នុងតបន់អាស៊ីប៉ាស៊ីហ្វិក អូសេអានី អាហ្វ្រិក អឺរ៉ុប និងអាមេរិក ។

ដោយឡែក នៅប្រទេសកម្ពុជាយើង សង្កេតឃើញ ផ្លែឈើ និងបន្លែហូបផ្លែជាច្រើនមុខរង ការបំផ្លាញដូចជា : ក្រូចគ្រប់ប្រភេទ ជំពូ ត្របែក ទៀប ពុទ្រា ស្វាយគ្រប់ប្រភេទ ល្ហុង មៀន ចេកគ្រប់ប្រភេទ ល្មុត ផ្លែទឹកដោះ ត្រសក់គ្រប់ប្រភេទ ត្រប់ ត្រឡាច ល្ពៅ ននោង...។ ល។ ការបំផ្លាញនេះយើង មិនទាន់មានវិធានការ មានប្រសិទ្ធភាព ទប់ស្កាត់ និង កំចាត់នៅឡើយ ។

## ២-លក្ខណៈរូបសាស្ត្រ និងជីវសាស្ត្រ

ប្រជាកសិករយើង តែងតែហៅថា ស្រាំង រឺ រុយមាស រឺ រុយក្បាលស្វា ដោយសំគាល់ពណ៌ភ្លឺៗ ពណ៌មាស រឺ បៃតងភ្លឺថ្លា។ វដ្ដជីវិតរបស់វា មានការវិវត្តពេញលេញ មេ ពង ដង្កូវ ដឹកឡឿ ហើយអាយុកាល របស់វាប្រែប្រួលទៅតាម species នីមួយៗ តែជាមធ្យមដង្កូវ អាចរស់នៅក្នុងផ្លែឈើ និង បំផ្លាញផ្លែឈើពី ៧-១៤ថ្ងៃ ។ សត្វពេញវ័យមិនបំផ្លាញផ្លែឈើទេ ។

## ៣-វិធានការបង្ការ និងកំចាត់

### • វិធានភូតគាមអនាម័យ

អនុវត្តបទដ្ឋានបច្ចេកទេស ច្បាប់ជាតិ និងអន្តរជាតិដែល បាននិងកំពុងធ្វើសុខដុមនីយកម្មក្នុងតំបន់ (ឧទា: ISPMN°1-ISPMN°29) និងអនុក្រិត្យឬប្រកាសផ្សេងៗទៀតដែលធ្វើឡើងស្របទៅនឹង អនុសញ្ញាការពារដំណាំអន្តរជាតិ (IPPC) ។

### • វិធានដាំដុះនិងអនាម័យ

-ការបង្ការល្អបំផុតគឺ រុំផ្លែឈើដោយ ក្រដាសកាសែត ឬថង់ ។ ត្រូវសំអាតប្រមូលកាកសំណល់ សំបក ស្លឹក មែកឈើ ឬ ផ្លែឈើដែលស្អុយជ្រុះដុតកំទេចចោល ដើម្បីកាត់ផ្ដាច់វដ្ដជីវិត នៃពពួករុយមាស ឬ រុយក្បាលស្វា ។

-យកផ្លែឈើដែល មានស្នាមបំផ្លាញ ដោយដង្កូវរុយ ជ្រមុជត្រាំក្នុងទឹក ៣-៤ថ្ងៃ ឬ ដាក់ថង់ប្លាស្ទិកខ្មៅបិទជិតហើយ ដាក់ហាលថ្ងៃបន្ទាប់មកយកផ្លែឈើនោះធ្វើជាចំណីសត្វឬបក្សី ។

### • វិធានការគីមី

គេអាចប្រើប្រាស់ថ្នាំកសិកម្ម ដែលមានសារធាតុសកម្ម malathion dimethoate និង fenthion ដោយបាញ់លើ រុក្ខជាតិទាំងមូល និងលើស្លឹក ឬ ផ្លែដែលជ្រុះជុំវិញដើមរុក្ខជាតិ រាល់សប្ដាហ៍ ដោយចាប់ផ្ដើម ២សប្ដាហ៍ មុននឹងផ្លែឈើបានផល ហើយរហូតដល់ប្រមូលផល ។ ប៉ុន្តែទង្វើបែបនេះធ្វើឱ្យបាត់បង់ សត្រូវធម្មជាតិ របស់រុយចោះផ្លែ ប៉ះពាល់ដល់សុខភាពអ្នក ហូបផ្លែឈើ និង អាចបន្សល់សំណល់ជាតិពុល លើផ្លែឈើលើស កំរិត MRLs ដែលមិនអាចនាំចេញ ទៅក្រៅប្រទេសបាន ។

### • *វិធានការជីវសាស្ត្រ( ការប្រើប្រាស់អន្ទាក់ Pheromone ME )*

គេប្រើប្រាស់អន្ទាក់ ME នេះ ដើម្បីកាត់បន្ថយ និង កំចាត់ពពួករុយចោះផ្លែបានយ៉ាងមានប្រសិទ្ធភាពដោយរួមផ្សំជាមួយវិធានការដាំដុះ ឬអនាម័យចំការដូចបានរៀបរាប់ខាងលើ ។



### ផលប្រយោជន៍នៃការប្រើប្រាស់អន្ទាក់ Pheromone

*- ចំណាយថវិការតិចនិងចំណេញពេលវេលា*

*- មានប្រសិទ្ធភាពល្អប្រសើរក្នុងការកាត់បន្ថយដង់ស៊ីតេប្រជាករនៃពពួករុយ លើដំណាំហូបផ្លែ ដោយមិនប៉ះពាល់ដល់សុខភាពអ្នកប្រើប្រាស់ និងហូបចុក*

*- ធានានូវគុណភាព និងរស់ជាតិផ្លែឈើ និងបន្លែហូបផ្លែ*

*- មិនប៉ះពាល់ដល់ បរិស្ថានធម្មជាតិ ( មិនសំលាប់សត្វមានប្រយោជន៍ដែលជាសត្រូវធម្មជាតិ នៃពពួករុយចង្រៃនេះ)*

*- ផ្លែឈើ និង បន្លែហូបផ្លែ គ្មានជាតិថ្នាំពុលធានាសុវត្ថិភាពដល់ អ្នកហូបចុក និងតំលៃទីផ្សារក្នុងស្រុក*

*- អាចនាំចេញទៅក្រៅប្រទេសប្រកួតប្រជែងលើទីផ្សារសេរីបានដោយ ទំលាយរបាំងបច្ចេកទេស (MRLs and Phyto sanitary requirements) ។*